ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានសម្រាប់ក្រុមបុរសស្រឡាញ់បុរស

## ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២

## ចាប់ពីម៉ោង: ៨:៣០ រហូតដល់ម៉ោង ១១:០០ ព្រឹក

**១.គោលបំណង**

-ពិភាក្សាការងារដើម្បីរៀបចំកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា។

-ពិនិត្យមើលបទអន្តរាគមន៍បង្ការបុរសស្រឡាញ់បុរស នៅកម្ពុជា សំរាប់ឆ្នាំ ២០១២

**២.កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន**

-កាលបរិច្ឆេទ:ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១២

-ទីកន្លែង:នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-វត្តមាន: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ RHAC BC N KHANA UNESCO and CSSD

-អវត្តមាន: MSIC FHI360 PSI UNAIDS (confirm for absence) MHSS MHC KDFO Pact Cambodia and KANHNHA

**៣.វិធីសាស្ត្រ**

-ជួបពិភាក្សាជាមួយសមាជិកក្រុមការងារលេខាធិការដ្ឋានក្រុមបុរសស្រឡាញ់បុរស

## ៤.លទ្ធផល

កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន សម្រាប់ក្រុមបុរសស្រឡាញ់បុរស ស្តីពីការពិនិត្យមើលបន្តពីកិច្ចប្រជុំលើកមុនក្នុងការប្រមូលបទអន្តរាគមន៍ និងទំហំថវិកា នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនៅកម្ពុជា ។ អញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ដោយឯកឧត្តម វេជ្ជ. តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស។ ជាកិច្ចចាប់ផ្តើម ឯកឧត្តម បានមានមតិស្វាគមន៍ និងអរគុណយ៉ាងជ្រាវជ្រៅចំពោះវត្តមានសមាជិកក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស ដែលបានចំណាយពេលវេលាចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារ។ អង្គប្រជុំបានពិភាក្សាលំអិតទៅតាមចំនុចនីមួយៗនៃប្រធានបទ និងបានសំរេចលទ្ធផល ដូចខាងក្រោមៈ

- កិច្ចប្រជុំប្រចាំត្រីមាសលើកទីពីរ នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរស នឹងរៀបចំនៅ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ដោយមានប្រធានបទដូចខាងក្រោមៈស

  - បទបង្ហាញពីសមិទ្ធិផលសកម្មភាពការងារបុរសស្រឡាញ់បុរសនៅកម្ពុជា ដែលបានសំរេច និងបញ្ហា ព្រមទាំងឧបសគ្គនានាដែលបានជួបប្រទះ ក្នុងពេលអនុវត្តការងាររយៈពេលប្រាំមួយខែដើមឆ្នាំ។

  -បទបង្ហាញពីបទអន្តរាគមន៍ដែលកំពង់អនុវត្តលើក្រុមបុរសស្រឡាញ់បុរស នៅកម្ពុជា

  -បទបង្ហាញពីការពិនិត្យមើលនូវតួនាទី និងភារៈកិច្ចក្នុងការរៀបចំផែនការប្រតិបត្តិ

  -បទបង្ហាញពីវឌ្ឍនភាព និងកែសំរួលយន្តការរបស់បណ្តាញចតុមុខ

  -បទបង្ហាញពីវឌ្ឍនភាពតំណាងក្រុមបុរសស្រឡាញ់បុរសនៅក្នុង (CCC) ដែលរៀបចំដោយអង្គការKHANA។

- កិច្ចប្រជុំលេខាធិការដ្ឋានក្រុមបុរសស្រឡាញ់បុរស នឹងរៀបចំនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១២ ដើម្បីពិនិត្យពិភាក្សា និងកែសំរួលលើពង្រាងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសលើកទីពីរ។

- ស្នើសុំឱ្យសមាជិកក្រុមការងារផ្ញើរ នូវរបាយការណ៍សមិទ្ធិផលដែលបានសំរេច និងឧបសគ្គ ព្រមទាំងបំពេញនូវបទអន្តរាគមន៍ដែលកំពង់អនុវត្តលើក្រុមបុរសស្រឡាញ់បុរសនៅកម្ពុជា ឱ្យបានមុនថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២។

- ស្នើឱ្យសមាជិករៀបចំពង្រាងអត្ថបទសង្ខេបសំរាប់ផ្តល់ឱ្យប្រព័ន្ធផ្សព្វផ្សាយ ដែលជាយន្តការមួយក្នុងការតស៊ូមតិ។

- សូមឱ្យ UNESCOពិនិត្យពិចារណាលើសំណើសុំថវិកា សំរាប់ធ្វើការបណ្តុះបណ្តាលដល់បណ្តារប្រព័ន្ធសារព័តមាន។

● ជូនព័ត៌មានដល់សមាជិក និងរៀបចំឯកសារកិច្ចប្រជុំប្រចាំត្រីមាសលើកទីពីរ ដោយបញ្ចូលទៅក្នុងគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

ជាទីបញ្ចប់ ឯកឧត្តម អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងអំណរគុណ និងកោតសរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់សមាជិក ដែលជាសកម្មជនដែលបាន សហការគ្នាល្អធ្វើឱ្យការងារឆ្លើយតបទៅការ ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ទទួលលទ្ធផលគួរឱ្យកោតសរសើរទោះបីមានជួបបញ្ហាមួយចំនួនក៏ដោយ ។

ភ្នំពេញថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

បានឃើញ និងពិនិត្យ

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

អគ្គលេខាធិការ